# សុន ឆ័យ មានគម្រោងនាំឪពុក ទឹម សាខន ទៅ សួរសុខទុក្ខលោកដោយផ្ទាល់ដល់ស្រុកយួន

KMS News Sept. 14 - 16, 2008



លោក សុន ឆ័យ អ្នកនាំពាក្យគណបក្សសមរង្ស៊ី



លោកតា ទឹម ចៀម ឪពុកដ៏ចាស់ជរារបស់លោក ទឹម សាខន

ដោយ : វិសាល

ទោះបីជាមន្ត្រីស្ថានទូតយួនប្រចាំស្រុកខ្មែរមិនទាន់មានការឆ្លើយតបទៅនឹងសំណើរបស់លោក *សុន ឆ័យ* អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីយ៉ាងណាក៏ដោយ ក៏លោកមានគម្រោងធ្វើដំណើរជាឯកជនជាមួយក្រុមគ្រួសារអតីតព្រះសង្ឃ *ទឹម សាខន* នៅដើមខែតុលា ឆ្នាំ២០០៨ដើម្បីទៅសួរសុខទុក្ខ

តទៅទំព័រ២ ន

**តមកពីទំព័រ១ ន**

លោកដោយផ្ទាល់ដល់ស្រុកយួនតែម្តង ។

គម្រោងការលោក *សុន ឆ័យ* ទៅសួរសុខទុក្ខលោក *ទឹម សាខន* នៅដើមខែតុលាខាងមុខនេះបន្ទាប់ពីមានព័ត៌មានថា "*លោក ទឹម សាខន កំពុងតែជាប់ឃុំក្នុងផ្ទះនៅខេត្តមាត់ជ្រូក ប្រទេសយួននៅឡើយទេ ទោះបីជាលោកត្រូវបានអាជ្ញាធរយួនដោះលែងពីពន្ធនាគាររួចហើយក៏ដោយ*" ។

លោក*សុនឆ័យ*អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី បានមានប្រសាសន៍ថា "*ខ្ញុំនឹងធ្វើដំណើរដោយរួមទាំងក្រុមគ្រួសារលោក ទឹម សាខន ផង មានឪពុកលោកជាដើមទៅសួរសុខទុក្ខលោកដោយផ្ទាល់*" ។

អ្នកតំណាងរាស្ត្រដែលមានថ្វីមាត់ឆ្មើមរូបនេះបានបញ្ជាក់ច្បាស់ថា "*យើងធ្វើបែបនេះមិនមែនក្នុងនាមគណបក្សស៊ីទេ គឺធ្វើឡើងក្នុងនាមជាអ្នកតំណាងរាស្ត្រម្នាក់ដែលទទួលការស្នើសុំពីប្រជាពលរដ្ឋឱ្យជួយដើម្បីទៅពិនិត្យមើលថា តើប្រជាពលរដ្ឋរបស់ខ្ញុំហ្នឹងមានទទួលរងនូវការគាបសង្កត់ដូចការចោទប្រកាន់ដែរ ឬក៏យ៉ាងណា*" ?

លោក*សុន ឆ័យ* បានឱ្យដឹងទៀតថា លោកបានដាក់លិខិតស្នើសុំជាផ្លូវការទៅស្ថានទូតយួនប្រចាំកម្ពុជាកាលពីថ្ងៃទី៨ ខែកញ្ញា កន្លងទៅនេះ ។ ប៉ុន្តែខាងស្ថានទូតយួនមិនទាន់បានឆ្លើយតបជាផ្លូវការទៅនឹងការស្នើសុំរបស់លោកនៅឡើយទេ ។

យ៉ាងណាក៏ដោយក៏អ្នកនាំពាក្យស្ថានទូតយួនឈ្មោះ *ទ្រិញ បាគីម* បាននិយាយតាមរបៀបរៀបជើងព្រួលទុកជាមុនថា ការធ្វើដំណើររបស់លោក *សុន ឆ័យ* នោះអាចនឹងប្រព្រឹត្តទៅបានលុះត្រាណាតែមានការអនុញ្ញាតត្រឹមត្រូវជាមុនសិន ។

*ទ្រិញ បាគីម* បានបញ្ជាក់បន្ថែមទៀតថា លោក *ទឹម សាខន* បានក្លាយជាប្រជាពលរដ្ឋធម្មតានៅក្នុងប្រទេសវៀតណាមទៅហើយ ។ ដូច្នេះលោក *ទឹម សាខន* នឹងពុំមានឧបសគ្គអ្វីទេក្នុងការទំនាក់ទំនងជាមួយក្រុមគ្រួសារឬសាច់ញាតិនោះ ។

ប៉ុន្តែលោក *អាង ច័ន្ទរិទ្ធ* ប្រធានអង្គការខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្សបានបញ្ចេញប្រតិកម្មថា "*លោក ទឹម សាខន កំពុងឃុំខ្លួននៅក្នុងផ្ទះនៅឯខេត្តមាត់ជ្រូកប្រទេសយួន និងមានជំងឺថែមទៀតផង*" ។

ទាក់ទិននឹងការរង់ចាំចម្លើយតបជាផ្លូវការពីស្ថានទូតយួនរបស់អ្នកតំណាងរាស្ត្រ *សុន ឆ័យ* នេះដែរ សហគមន៍ខ្មែរកម្ពុជាក្រោមដែលដឹកនាំដោយលោក *ថាច់ សេដ្ឋា* ក៏ដូចជាអង្គការសមាគមខ្មែរកម្ពុជាក្រោមមួយចំនួនទៀតកំពុងតែរង់ចាំទទួលចម្លើយពីស្ថានទូតយួនប្រចាំក្រុងភ្នំពេញដើម្បីបានទៅសួរសុខទុក្ខលោក *ទឹម សាខន* ដែលកំពុងមានជំងឺ ជាទម្ងន់ និងកំពុងតែរស់នៅដោយគ្មានសេរីភាពពិតប្រាកដនៅឯខេត្តមាត់ជ្រូកប្រទេសយួន ។

អង្គការសមាគមខ្មែរកម្ពុជាក្រោមដែលរួមមានទាំងសហគមន៍ខ្មែរកម្ពុជាក្រោមរបស់លោក *ថាច់ សេដ្ឋា* ផងនោះបានសរសេរលិខិតមួយច្បាប់ផ្ញើទៅស្ថានទូតយួនកាលពីចុងខែសីហា ដោយបានស្នើសុំការអនុញ្ញាតឱ្យពួកគេបានទៅជួបលោក *ទឹម សាខន* អតីតចៅអធិការវត្តភ្នំដិនខាងជើង ។ ហើយបើតាមការលេចឮព័ត៌មានមកនោះគឺលោក *ទឹម សាខន* កំពុងមានជំងឺ និងត្រូវគេឃុំខ្លួនលោកនៅក្នុងផ្ទះទៀតផង ។

លិខិតនោះបានស្នើសុំអនុញ្ញាតឱ្យគណៈប្រតិភូអង្គការសមាគមខ្មែរកម្ពុជាក្រោមជួបលោក*ទឹមសាខន* ដើម្បីបញ្ជាក់ការពិតឱ្យបានច្បាស់ ជៀសវាងការយល់ច្រឡំចំពោះទង្វើរបស់អាជ្ញាធរយួនកុម្មុយនីស្តតទៅទៀត ។

យ៉ាងណាក៏ដោយ លោក *ថាច់ សេដ្ឋា* ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោមបានថ្លែងថា លោកកំពុងរង់ចាំការឆ្លើយតបពីស្ថានទូតយួន ព្រោះរហូតមកដល់ពេលនេះពុំទាន់មានចម្លើយគួរឱ្យទុកចិត្តណាមួយពីស្ថានទូតយួននៅឡើយទេ ។

លោក *ថាច់ សេដ្ឋា* បានមានប្រសាសន៍ថា "*ប្រសិនបើពុំមានការសម្ងាត់អ្វីពីស្ថានភាពរស់នៅរបស់លោក ទឹម សាខន ទេ គួរតែស្ថានទូតយួនអនុញ្ញាតឱ្យពួកយើងទៅជួបសួរសុខទុក្ខលោក ទឹម សាខន ដោយផ្ទាល់ផង*" ។

មន្ត្រីអង្គការខ្មែរកម្ពុជាក្រោមមួយរូបទៀតបានលើកឡើងថា យើងមានការព្រួយបារម្ភពីសុខភាព និងសន្តិសុខផ្ទាល់ខ្លួនរបស់លោក*ទឹមសាខន*ណាស់ ។ សំខាន់គឺយើងចង់ដឹងពីប្រវត្តិនៃការផ្សឹកនិងការដាក់ពន្ធនាគារលោកតែម្តង ព្រោះសំណើដែលយើងបានស្នើកាលពីមុនមកនោះ មិនទាន់បានទទួលនូវការឆ្លើយតបសោះ ។

ប៉ុន្តែបើសម្រាប់អ្នកនាំពាក្យក្រសួងមហាផ្ទៃឈ្មោះ *ខៀវ សុភ័គ* វិញ គាត់បាននិយាយតាមរបៀបគ្មានការឈឺឆ្អាលថា "*វាពិបាកណាស់ចំពោះអាជ្ញាធរកម្ពុជាក្នុងការធ្វើអន្តរាគមន៍នៅក្នុងករណីនេះ ដោយសារលោក ទឹម សាខន កំពុងស្ថិតនៅក្នុងប្រទេសវៀតណាមហើយគាត់ក៏ជាជនជាតិវៀតណាមដែរ ពិសេសគឺនៅទីនោះមិនអាចមានសញ្ជាតិពីរបានទេ*" ។

ទោះជាដូច្នេះក្តី ក៏លោក *សុន ឆ័យ* អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីនៅតែមានប្រសាសន៍ដោយទទូចថាលោកនិងក្រុមគ្រួសារលោក *ទឹម សាខន* គ្រោងនឹងធ្វើដំណើរទៅសួរសុខទុក្ខលោកដោយផ្ទាល់នៅឯស្រុកយួននាដើមខែតុលាខាងមុខនេះដែរ ។

ម្យ៉ាងទៀតអង្គការសមាគមខ្មែរកម្ពុជាក្រោមមួយចំនួនដែលមានការងារផ្នែកការពារសិទ្ធិមនុស្សនោះ ក៏ទំនងជាកំពុងរង់ចាំមើលការសម្រេចចុងក្រោយរបស់ស្ថានទូតយួនដែរ ។ ព្រោះគេជឿថា "*ប្រសិនបើពុំមានការសម្ងាត់អ្វីពីស្ថានភាពរស់នៅរបស់លោក ទឹម សាខន ទេ ស្ថានទូតយួនប្រាកដជាអនុញ្ញាតឱ្យមានការទៅជួបសួរសុខទុក្ខលោក ទឹម សាខន ដោយផ្ទាល់ជាមិនខាន*"៕